គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បោះពុម្ព និងផ្សព្វផ្សាយ

ដោយ គ.ជ.ប

ឆ្នាំ២០២២



អាសយដ្ឋាន : អគារ គ.ជ.ប វិថីវិរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

អ៊ីម៉ែល : info@nec.gov.kh

គេហទំព័រ : www.nec.gov.kh, www.voterlist.nec.gov.kh

Facebook : National Election Committee គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

Application : NEC KH


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

# ស្តីពី

# ការឃោសនាបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

(ថ្ងៃបោះឆ្នោត នៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២)

# អារម្ភកថា

សៀវភៅណែនាំស្ដីពី ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានចងក្រងឡើងជាឯកសារសម្រាប់ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ ពិសេសគណបក្សនយោបាយទាំងអស់ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យងាយស្រួលយល់អំពីបទបញ្ញា និងនីតិវិធី ក្នុងការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ សៀវភៅនេះជាជំនួយស្មារតីក្នុងការអនុវត្តសកម្មភាពឃោសនាបោះឆ្នោតផ្ទាល់ និងការអនុវត្តសកម្មភាពផ្សេងៗទៀតដែលទាក់ទងដល់ការឃោសនាបោះឆ្នោត។

ខ្លឹមសារក្នុងសៀវភៅនេះត្រូវបានដកស្រង់ជំពូកទី៧ ស្ដីពីការឃោសនាបោះឆ្នោត និងជំពូកទី៨ ស្ដីពីអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ចេញពីបទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងត្រូវបានបញ្ចូលឧបសម្ព័ន្ធចំនួន៣ គឺ៖

- សម្រង់ជំពូកទី៧ ស្ដីពីការឃោសនាបោះឆ្នោត នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- សម្រង់មាត្រាមួយចំនួនក្នុងជំពូកទី១៤ ស្ដីពីទោសប្បញ្ញត្តិ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។



# មាតិកា

ទំព័រ

**អារម្ភកថា** ---------- i
**មាតិកា** ---------- ii
**អក្សរកាត់** ---------- iii

**១- បទបញ្ញា និងនីតិវិធី ជំពូកទី ៧ "ការឃោសនាបោះឆ្នោត"**
- បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត ---------- ១
- សម្ភារអប់រំអ្នកបោះឆ្នោត ---------- ២៥
- រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ ---------- ៣០
- ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ------ ៤២

**២- បទបញ្ញា និងនីតិវិធី សម្រង់ជំពូកទី៨ ប្រការ ៨.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ** ---------- ៤៥

**៣- ឧបសម្ព័ន្ធ**

ក. សម្រង់ជំពូកទី៧ ស្ដីពីការឃោសនាបោះឆ្នោត នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ---------- ៥០

ខ. សម្រង់មាត្រាមួយចំនួនក្នុងជំពូកទី១៤ ស្ដីពីទោសប្បញ្ញត្តិនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ --- ៦២

គ. ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២---------- ៦៩

# អក្សរកាត់

| | |
|---|---|
| - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| - គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| - គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| - គណៈកម្មការការិយាល័យបោះឆ្នោត | គ.ក.ប |
| - គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត | គ.ក.រ |
| - ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| - ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ច.ប.ឃ.ស |
| - បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ប.ន.ឃ.ស |



# បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

## ជំពូកទី ៧

## ការឃោសនាបោះឆ្នោត

### បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត

**ប្រការ ៧.១**.-

អនុលោមតាម ច.ប.ឃ.ស ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយ ដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។ សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយមានដូចជា៖

៧.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន។

៧.១.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះ-ឆ្នោត។

៧.១.៣ ការជួបជុំ ឬការឃោសនាតាមផ្ទះ។

៧.១.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន។

៧.១.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ។

៧.១.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា។

៧.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យខ្លួន ឬគណបក្សនយោបាយរបស់ខ្លួន។

៧.១.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬ/និងបេក្ខជនជូនអ្នកបោះឆ្នោត។

៧.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្ដារបិទប្រកាសផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន។

៧.១.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយ។

៧.១.១១ ការរៀបចំកម្មវិធីប្រកួតកីឡាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។



**ប្រការ ៧.២.-**

ការឃោសនាបោះឆ្នោតត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត។

៧.២.១ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្ដើមពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់។

៧.២.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក។

៧.២.៣ សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេង ត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ

- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិក្សា លើកលែងតែនៅក្រៅពេលម៉ោងសិក្សា។

៧.២.៤ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពបុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យភាន់ច្រឡំក្នុងដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្ទង់មតិត្រូវបញ្ជាក់អំពីប្រភពផ្តល់ព័ត៌មាន ពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសមកស្ទង់មតិ កម្រិតលម្អៀងនៃលទ្ធផល



ព្រមទាំងត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព។

៧.២.៥ គ្រប់សកម្មភាពឃោសនាដែលមានចែងក្នុងជំពូកទី៧ នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ នឹងត្រូវទទួលការពិន័យតាម ច.ប.ឃ.ស។

**ប្រការ ៧.៣.-**

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនាបោះឆ្នោតបាន នៅទីសាធារណៈ ឬនៅទីស្នាក់ការរបស់ខ្លួន ឬទីកន្លែងឯកជន ឬលំនៅឋានឯកជន ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៧.៣.១ ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៧.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនាសម្រាប់គណបក្សនយោបាយមិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៧.៣.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យ-

ស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណរបស់គណបក្សណាមួយបាន។

៧.៣.៤ ស្លាកសញ្ញា ឬសម្ភារឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុត នៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៧.៣.៥ គណបក្សនយោបាយ ត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

**ប្រការ ៧.៤.-**

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្ស



នយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៧.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ដូចជា រថយន្ត ត្រីចក្រយានយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល។

៧.៤.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុន ត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប។

**ប្រការ ៧.៥.-**

ការស្លៀកពាក់ (សម្លៀកបំពាក់-មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការ

ស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត។

**ប្រការ ៧.៦**.-

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតយ៉ាងច្រើន ២ (ពីរ) ដង នៅក្នុងឃុំ សង្កាត់ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.៦.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ ដូចខាងក្រោម៖

៧.៦.១.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ដែលសាមីគណបក្សនយោបាយបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.៦.១.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងឃុំ សង្កាត់។

៧.៦.១.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំដូចខាងក្រោម៖



- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង
- មានអ្នកចូលរួមចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោត មានដូចខាងក្រោម៖
  - រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ២០ (ម្ភៃ) គ្រឿង
  - ជលយានគ្រប់ប្រភេទ ចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ។

៧.៦.២ គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សបយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួន

ឃោសនា។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

៧.៦.២.១ នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ។

៧.៦.២.២ កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន។

៧.៦.២.៣ ទីតាំងប្រមូលផ្តុំ និងតម្រាយផ្លូវដែលត្រូវហែ-ក្បួន។

៧.៦.២.៤ ចំនួនអ្នកចូលរួម។

៧.៦.២.៥ ចំនួនយានជំនិះតាមប្រភេទនីមួយៗ។

៧.៦.៣ ក្នុងករណីគណបក្សនយោបាយមានបំណងហែក្បួនឃោសនាឆ្លងកាត់ឃុំ សង្កាត់ពីរ ឬច្រើនដែលមានព្រំប្រទល់ជាប់គ្នា ដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សាមីគណបក្សនយោបាយនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សប ពាក់ព័ន្ធយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា។ ឃុំ សង្កាត់ពាក់ព័ន្ធដែលសាមីគណបក្សនយោបាយបានហែក្បួនឆ្លងកាត់នោះ ត្រូវចាត់ទុកថា បានហែមួយដងរួចហើយ។

៧.៦.៤ គឃ.សប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួលទីកន្លែង ផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ។

៧.៦.៥ ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អ តាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**ប្រការ ៧.៧.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវធ្វើសកម្មភាព ដូចខាងក្រោម ៖

៧.៧.១ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរដែលមានន័យ គំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។

៧.៧.២ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣ ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ ដូចតទៅ ៖

៧.៧.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ។

៧.៧.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៧.៧.៣.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។



៧.៧.៣.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៧.៧.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

## ប្រការ ៧.៨.-

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

## ប្រការ ៧.៩.-

ក្នុងដំណើរការបោះឆ្នោត មេភូមិ និងជំនួយការមេភូមិ ត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅណែនាំស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ និងជំនួយការមេភូមិ ក្នុង

ដំណើរការរៀបចំការបោះឆ្នោតរបស់ គ.ជ.ប។ មេភូមិ និងជំនួយការមេភូមិ មានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ ដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើស។ ក៏ប៉ុន្តែ សកម្មភាពទាំងនោះ ត្រូវធ្វើក្នុងឋានៈជាបុគ្គលឯកជន ពោលគឺមិនមែនក្នុងតួនាទីជាមេភូមិ និងជំនួយការមេភូមិឡើយ។ មេភូមិ និងជំនួយការមេភូមិ ត្រូវព្យាយាមធ្វើឱ្យបាននូវសកម្មភាព ដូចខាងក្រោម៖

៧.៩.១ ផ្តល់សេវា និងព័ត៌មានដូចគ្នាៗជូនដល់អ្នកភូមិទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា។

៧.៩.២ ធានាថាការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗដទៃទៀត ត្រូវបានអនុវត្តដោយយុត្តិធម៌ ដោយស្មើភាព និងអស់ពីកម្លាំងចិត្តដល់អ្នកភូមិគ្រប់ៗរូប និងដោយឥតគិតថ្លៃ។

៧.៩.៣ ត្រូវប្រកាន់ខ្ជាប់ឥរិយាបថ អព្យាក្រឹត ឥតលម្អៀងនៅក្នុងការបំពេញការងារទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត។

៧.៩.៤ ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូបឱ្យបានស្មើគ្នា។

៧.៩.៥ ផ្តល់កិច្ចសហការជាមួយនឹង គឃ.សប គធ.ខប និង គ.ជ.ប ទាក់ទងនឹងការអនុវត្តការងារបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានអំពីការបោះឆ្នោត ការចែកខិត្តប័ណ្ណ



សៀវភៅព័ត៌មាន ឬប័ណ្ណប្រកាសផ្សេងៗ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

**ប្រការ ៧.១០.-**

មេភូមិ និងជំនួយការមេភូមិ ត្រូវចៀសវាងការគំរាមកំហែង ឬបង្ហាញឥរិយាបថលម្អៀងក្នុងការអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងការបោះឆ្នោត។ មេភូមិ និងជំនួយការមេភូមិមិនត្រូវអនុវត្ត ដូចខាងក្រោម៖

៧.១០.១ បង្ហាញការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយជាសាធារណៈ។

៧.១០.២ ប្រើប្រាស់ឥទ្ធិពល ឬតួនាទីរបស់ខ្លួនរំលោភលើសិទ្ធិសម្រេចរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត។ ការរំលោភលើសិទ្ធិរួមមាន៖

៧.១០.២.១ បំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោតក្នុងគោលបំណងឱ្យអ្នកបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.២ សួរនាំអ្នកបោះឆ្នោត ឬចង់ដឹងអំពីការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោត។

៧.១០.២.៣ ដកហូត អ.ខ ឬ ឯ.អ ពីប្រជាពលរដ្ឋ។

៧.១០.២.៤ ជ្រៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោត ក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី ដើម្បីគាំទ្រដល់

គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.៥ អូសទាញអ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.៦ រារាំងអ្នកភូមិគ្រប់រូបដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំសាធារណៈរបស់ភូមិ ឃុំ សង្កាត់ ឬរបស់គណបក្សនយោបាយណាមួយ ឬរារាំងការទទួលព័ត៌មានពីគណបក្សនយោបាយណាមួយ។

៧.១០.៣ ធ្វើសកម្មភាពណាមួយ ទោះដោយប្រយោលក្តី ឬផ្ទាល់ក្តី ដើម្បីបំភិតបំភ័យ គំរាមកំហែងអ្នកបោះឆ្នោត ដែលនាំឱ្យបាត់សេរីភាពនៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត។

៧.១០.៤ ធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយណាមួយ ដែលនាំឱ្យជះឥទ្ធិពលដល់អ្នកភូមិ និងបាត់បង់ភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយផ្សេងទៀត។

៧.១០.៥ ផ្អិបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានដោយមានការរើសអើងចំពោះអ្នកគាំទ្រគណបក្សនយោបាយណាមួយ។



**ប្រការ ៧.១១**.-

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម៖

៧.១១.១ ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តួចផ្តើម ឬការចូលរួមឃោសនារួមមាន ៖

៧.១១.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.២ ការចូលរួមក្នុងក្បួនដង្ហែ ការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៧.១១.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ និងការបង្ហាញភាពលម្អៀង រួមមាន ៖

៧.១១.២.១ ការស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។



៧.១១.៣ ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន ៖

៧.១១.៣.១ ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៣.២ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ក្បួនដង្ហែឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៤ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

## ប្រការ ៧.១២.-

មុននឹងបើកការឃោសនាបោះឆ្នោត គជ.ខប និង គឃ.សប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្រោមប្រការ ៧.៧ ប្រការ ៧.៨ និងប្រការ ៧.៩ ខាងលើ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត។

## ប្រការ ៧.១៣.-

គជ.ខប និង គឃ.សប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែម តាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី ៖

៧.១៣.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត។

៧.១៣.២ ជម្រាបជូនជាសង្ខេបពី ប.ន.ឃ.ស។

៧.១៣.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ។

៧.១៣.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត។

## ប្រការ ៧.១៤.-

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍



ដែលចែងក្នុង ច.ប.ឃ.ស និងក្រមសីលធម៌ គោរពតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៧.១៤.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ។

៧.១៤.២ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ។

៧.១៤.៣ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៧.១៤.៤ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។

៧.១៤.៥ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ

មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ។

៧.១៥.៦ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

៧.១៥.៧ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័នអង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត។

៧.១៥.៨ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវគំរាម-កំហែង ឬបំភិតបំភ័យ ដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះ ឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៧.១៥.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៧.១៥.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម ។

៧.១៥.៨.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់។

៧.១៥.៨.៤ ការរំលោភដោយពាក្យសម្តីថានឹងធ្វើទុក្ខទោសដល់រាងកាយ។

៧.១៥.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ។

៧.១៥.៨.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយ-លក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។

៧.១៥.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ។

៧.១៤.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន។

៧.១៤.៨.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន។

៧.១៤.៨.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬធ្វើឱ្យខូចផលប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

៧.១៤.៨.១១ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត។

៧.១៤.៨.១២ ការកំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា។



**ប្រការ ៧.១៥.-**

គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៧.១៤ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ឃ.ស។

## សម្ភារអប់រំអ្នកបោះឆ្នោត

**ប្រការ ៧.១៦.-**

អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលមាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈជាសេនាធិការ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត។

៧.១៦.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់។

៧.១៦.២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងព័ត៌មានជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល

និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់-ទំនងសាធារណៈ។

៧.១៦.៣ សម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវតែអព្យាក្រឹត និងមិនលម្អៀង។ សម្ភារនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

៧.១៦.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ។

៧.១៦.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាមច្បាប់បោះឆ្នោត ហើយនិងតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម និងណែនាំដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ។



៧.១៦.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះ-ឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ។

៧.១៦.៧ ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។ ម្ចាស់សម្ភារអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៧.១៦.៨ ក្នុងករណីដែលមានការស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយ ដែលមានចែងក្រោមប្រការ ៧.១៨ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសំណើពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា សុំឱ្យជួយពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារអប់រំនោះ។ ក្នុងករណីពិនិត្យឃើញថាសម្ភារ ឬខ្លឹមសារអប់រំមិនសមស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីទេ គណៈកម្មការសម្របសម្រួល ត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួល ពិនិត្យឡើងវិញ។ ក្នុងករណី

គណៈកម្មការសម្របសម្រួល ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារៈអប់រំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន។

៧.១៦.៩ សម្ភារៈអប់រំដែលត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប ដូចជា៖

៧.១៦.៩.១ ស្ប៉ុតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ។

៧.១៦.៩.២ កាសែ្សតម៉ាញ៉េ ឬខ្សែអាត់សំឡេង។

៧.១៦.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា។

៧.១៦.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត។

៧.១៦.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន។

៧.១៦.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក។

៧.១៦.១០ សម្ភារៈដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ។



៧.១៦.១១ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម ដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃ ច.ប.ឃ.ស។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារៈអប់រំដែលខ្លួនបានផលិតនោះត្រូវបានរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ឃ.ស និង ប.ន.ឃ.ស គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារៈនោះទាំងស្រុងតែម្តង។ សម្ភារៈដែលរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចចំណុច ៧.១៧.៥ ខាងក្រោម។

៧.១៦.១២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ។

៧.១៦.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារអប់រំទាំងអស់ដែលមិនគោរពតាមចំណុច ៧.១៦.៣ ចំណុច ៧.១៦.១២ និងចំណុច ៧.១៧.៥ សាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវទទួលទោសតាម ច.ប.ឃ.ស។

## រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ

**ប្រការ ៧.១៧.-**

យោងតាមប្រការ ៧.២ នៃ ប.ន.ឃ.ស នេះ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយបានដូចជា៖

៧.១៧.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត។

៧.១៧.២ ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព។

៧.១៧.២.១ អត្ថបទឃោសនា។

៧.១៧.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ។

៧.១៧.២.៣ ការសូត្រកំណាព្យ។

៧.១៧.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង។



៧.១៧.២.៥ សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្ត-ផ្ទាល់។

៧.១៧.២.៦ ការសម្តែងសិល្បៈ។

៧.១៧.២.៧ ការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូជាសាធារណៈ ឬទីធ្លាសាធា-រណៈ។

៧.១៧.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការរបស់ខ្លួន។

៧.១៧.៣ ដោយយោងលើរូបភាព និងសម្ភារឃោសនាបោះឆ្នោតដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតរួមមាន៖

៧.១៧.៣.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្តវីដេអូ។

៧.១៧.៣.២ ប៉េងប៉ោង ឬ/និងបង្គោះខ្លែង។

៧.១៧.៣.៣ សម្ភារបោះពុម្ពមានជាអាទិ៍ រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាក-សញ្ញា លោហៈខ្វាស់ បដា។

៧.១៧.៣.៤ ការស្រែកតាមទីសាធារណៈ។

៧.១៧.៤ គ្រប់សម្ភារ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និង

គណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន)។

៧.១៧.៥ សម្ភារអប់រំ និងសម្ភារឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយ ដូចខាងក្រោម៖

៧.១៧.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត។

៧.១៧.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្តែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍។

៧.១៧.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រួសភាពភ័យខ្លាចធ្វើឱ្យភាន់ច្រឡំ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម។



៧.១៧.៥.៤ ប្រើប្រាស់រូបភាព ឬភាសា ដែលមានព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត។

៧.១៧.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារអប់រំ និងសម្ភារឃោសនាដែលត្រូវបានរកឃើញថារំលោភចំណុច ៧.១៧.៥ ខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ។

៧.១៧.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារអប់រំ និងសម្ភារឃោសនាដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៧ នៃ ប.ន.ឃ.ស នេះ។

៧.១៧.៨ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត។

៧.១៧.៩ ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ។

**ប្រការ ៧.១៨.-**

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅថា "គណៈកម្មការសម្របសម្រួល" តាមសេចក្តីសម្រេចរបស់ គ.ជ.ប ដើម្បីត្រួតពិនិត្យសម្ភារអប់រំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារឃោសនារបស់គណបក្សនយោបាយក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹង ព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព និងសមធម៌។

៧.១៨.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួល ត្រូវបានកំណត់ដូចខាងក្រោម៖

៧.១៨.១.១ ត្រួតពិនិត្យ និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៧.១៨.១.២ ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាងដទៃទៀត ដោយយោងតាម ច.ប.ឃ.ស និងយោងតាមចំណុច ៧.១៩.៨ ចំណុច ៧.១៧.៥ និងចំណុច ៧.១៧.៨ នៃ ប.ន.ឃ.ស នេះ។

៧.១៨.១.៣ សម្របសម្រួលកម្មវិធីស្មើភាព និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.១៨.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ក្នុងពេលឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយ ផ្អែកតាមគោលការណ៍ស្មើភាព និងសមធម៌ និងតាមលំដាប់មុនក្រោយ។

៧.១៨.១.៥ សម្របសម្រួលជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព និងសមធម៌ សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.១៨.២ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍រៀបចំកម្មវិធីស្មើភាព និងសមធម៌ ជូនគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជននៃគណបក្សនយោ-

បាយឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស ជាផ្លូវការ មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដល់អ្នកបោះឆ្នោតតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍របស់ គ.ជ.ប និងតាមលំដាប់ពេលមុនក្រោយ។

៧.១៨.២.១ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះ ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព និងសមធម៌ ហើយត្រូវមានបទបញ្ញាមួយសម្រាប់ថតកម្មវិធី ដែលអនុម័តដោយ គ.ជ.ប។

៧.១៨.២.២ គណៈកម្មការសម្របសម្រួល ត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព និងសមធម៌របស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ។

៧.១៨.៣ កម្មវិធីស្មើភាព និងសមធម៌ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ ដូចខាងក្រោម ៖



៧.១៨.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទរវាងបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាងគណបក្សនយោបាយអំពីកម្មវិធីនយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

៧.១៨.៣.២ កម្មវិធីចាក់ផ្សាយស្ប៉ុតរបស់គណបក្ស-នយោបាយតាមវិទ្យុ និងទូរទស្សន៍រដ្ឋ។

៧.១៨.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប។

៧.១៨.៤ គណៈកម្មការសម្របសម្រួល ត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ញា និងនីតិវិធី ក្រមសីលធម៌ និងគោលការណ៍ណែនាំផ្សេងៗរបស់ គ.ជ.ប។

**ប្រការ ៧.១៩.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និង

តាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ។ គណបក្សនយោបាយ ឬបេក្ខជន ដែលមានបំណងជួលរោងមហោស្រព ឬមណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រង យ៉ាងហោច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះ ១ (មួយ) ច្បាប់ដល់ គឃ.សប។ អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ។

៧.១៩.១ គធ.ខប និង គឃ.សប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត។

៧.១៩.២ បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹង ដូចមានចែងក្នុងប្រការ ៧.១៩ គឃ.សប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួលអំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនា។

៧.១៩.៣ គឃ.សប ត្រូវមានសៀវភៅចុះលិខិតចម្លងនៃពាក្យស្នើសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបញ្ជីបេក្ខជន ដែលបានចម្លងជូនដើម្បីឱ្យបានដឹងថា គណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាមុន និងគណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាបន្តបន្ទាប់។



៧.១៩.៤ គឃ.សប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់លំដោយនៃការស្នើសុំប្រើប្រាស់ទីធ្លាសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ.សប ១ (មួយ) ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនា ១ (មួយ) ច្បាប់។

៧.១៩.៥ គធ.ខប គឃ.សប ជាអ្នកសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាទាំងឡាយណាដែលផ្ទុយនឹង ច.ប.ឃ.ស និង ប.ន.ឃ.ស។

## ប្រការ ៧.២០.-

គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ។

## ប្រការ ៧.២១.-

គណបក្សនយោបាយ ឬ/និងបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅតាមកន្លែងឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សប យ៉ាងតិច ៣ (បី) ថ្ងៃ

មុនថ្ងៃប្រជុំឃោសនា។ អ្នកគ្រប់គ្រងទីកន្លែង ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលមានបំណងសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើតម្លៃស្មើៗគ្នា និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការសុំជួល។

**ប្រការ ៧.២២.-**

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះ រួមមាន ៖

៧.២២.១ ការនិយាយជៀមដាមប្រមាថ មាក់ងាយ។

៧.២២.២ ការធ្វើទុក្ខទោសដល់រាងកាយ។

៧.២២.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់។

៧.២២.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ។

៧.២២.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមកាលកំណត់។

៧.២២.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទច់បង្អាក់មិនឱ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត។

៧.២២.៧ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ។

៧.២២.៨ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.២២.៩ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ។

៧.២២.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ។

**ប្រការ ៧.២៣.-**

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារ សន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៧.២៣.១ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព

និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការឃោសនាបោះ-ឆ្នោត។

៧.២៣.២ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវ ដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នា ក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៧.២៣.៣ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណ នៃអង្គពិធីឃោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ។

៧.២៣.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គឃ.ខប ត្រូវតាមដានជារៀងរាល់ថ្ងៃអំពីកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងឃុំ សង្កាត់ និងត្រូវជូនព័ត៌មានទៅ គធ.ខប ជារៀងរាល់ថ្ងៃ។ គធ.ខប ត្រូវសរុបសភាពការណ៍សន្តិសុខ សុវត្ថិភាព និងរាយការណ៍ជូន គ.ជ.ប ជារៀងរាល់ថ្ងៃ។

## ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

### ប្រការ ៧.២៤.-

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅ



នៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន។

### ប្រការ ៧.២៥.-

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វ-ផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។

### ប្រការ ៧.២៦.-

គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ ទាំងឯកជន ត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

### ប្រការ ៧.២៧.-

រាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ១៤ នៃ ប.ន.ឃ.ស នេះ។

# បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ សម្រង់ជំពូកទី ៨ ប្រការ ៨.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

**ប្រការ ៨.៥.-**

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យ ដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសរើស កបឃ.ស មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់នៅ គ.ជ.ប។

៨.៥.១ អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលមាននាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈជាសេនាធិការ ត្រូវអនុវត្តការងារទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានឯករាជ្យដែលចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសរើស កបឃ.ស។

៨.៥.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យ តាមការស្នើសុំដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ www.nec.gov.kh។



៨.៥.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោត រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៨.៥.២.២ រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានអន្តរជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោត រហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៨.៥.៣ ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួន ដូចខាងក្រោម៖

៨.៥.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើប័ណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃប័ណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬប័ណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព

- ប្រវត្តិរូបសង្ខេប។

៨.៥.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើប័ណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃប័ណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬប័ណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សម្រាប់ជនបរទេស)។

៨.៥.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់ជាមួយនូវ៖

- ច្បាប់ចម្លងនៃលិខិតឆ្លងដែន



- ប័ណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប។

៨.៥.៣.៤ សម្រាប់អ្នកសារព័ត៌មានឯករាជ្យ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃប័ណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយ ដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ។

៨.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកសារព័ត៌មានជាតិ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀតក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតបដិសេធ។

៨.៥.៥ គ.ជ.ប ត្រូវពិនិត្យ សម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ។

៨.៥.៦ គ.ជ.ប ត្រូវបោះពុម្ពប័ណ្ណសម្គាល់អ្នកសារព័ត៌មានជាតិ និងប័ណ្ណសម្គាល់អ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មាន ដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៨.៥.៧ អ្នកសារព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ឃ.ស ប.ន.ឃ.ស ក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារព័ត៌មាន។

៨.៥.៨ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ដោយត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស និងគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។



៨.៥.៩ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មានសិទ្ធិថត និងយកព័ត៌មាន។

៨.៥.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន គ.ក.ប/គ.ក.រ ជាមុន។

៨.៥.១១ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៥.១២ អ្នកសារព័ត៌មានមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិក គឃ.សប ឬសមាជិក គ.ក.ប/គ.ក.រ ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ។

# ឧបសម្ព័ន្ធ ក
# សម្រង់ជំពូកទី៧ ស្តីពីការឃោសនាបោះឆ្នោត
# នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស
# ក្រុមប្រឹក្សាឃុំ សង្កាត់

## មាត្រា ៦៧.-

ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយ ដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជន ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត។

## មាត្រា ៦៨.-

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ មានដូចជា៖

- ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន
- ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់ យ៉ាងច្រើន ០២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត
- ការជួបជុំ ឬការឃោសនាតាមផ្ទះ
- ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន



- ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ
- សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា
- សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ
- សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជន ជូនអ្នកបោះឆ្នោត
- សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាសផ្សាយ
- ការប្រគុំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត
- ការរៀបចំកម្មវិធីប្រកួតកីឡា។

## មាត្រា ៦៩.-

ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយមិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណរបស់គណបក្សណាមួយបាន។

ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការ អចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

## មាត្រា ៧០.-

ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត។



ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិអំពីកិច្ចការបោះឆ្នោត ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

## មាត្រា ៧១.-

គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ

ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណង ទិញទឹកចិត្តអ្នកបោះឆ្នោត។

**មាត្រា ៧២.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវៈ

- ប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ
- ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ
- ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។

ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត ដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ចត្រូវបានកំណត់ដូចតទៅៈ



- ជាសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់។
- ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

**មាត្រា ៧៣.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

**មាត្រា ៧៤.-**

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម៖

- ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តួចផ្តើម ឬការចូលរួមឃោសនា រួមមាន៖
    - ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
    - ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
    - ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
    - ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ។
- ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន៖
    - ការស្នងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
    - ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
    - ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យ ប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

- ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

- ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ដែលរួមមាន៖

  - ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
  - ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
  - ការផ្តល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

**មាត្រា ៧៥.-**

ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុង



ការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

**មាត្រា ៧៦.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌ គោរពតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

របៀប បែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹង ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ៧៧.-**

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយ ដែលបាន

ចុះបញ្ជីឈរឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ។

**មាត្រា ៧៨.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់ឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយតាមកាលបរិច្ឆេទនៃការស្នើសុំ។

គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោច ០៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះមួយច្បាប់ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

អ្នកគ្រប់គ្រង ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឱ្យលើស ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ។

**មាត្រា ៧៩.-**

ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។



**មាត្រា ៨០.-**

គណបក្សនយោបាយនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ឬបេក្ខជន អាចធ្វើការឃោសនានៅតាមកន្លែងឯកជនបាន តែត្រូវមានការយល់ព្រមជាមួយម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាមុនទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតអំពីកាលបរិច្ឆេទនៃការឃោសនាបោះឆ្នោតនោះ។

**មាត្រា ៨១.-**

គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រមិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពរបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រផ្សេងទៀត។

**មាត្រា ៨២.-**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

# ឧបសម្ព័ន្ធ ខ
# សម្រង់មាត្រាមួយចំនួនក្នុងជំពូកទី១៤ ស្តីពីទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់

## មាត្រា ១៧១.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះ-ឆ្នោត តាមការកំណត់



- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្ម ដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## មាត្រា ១៧២.-

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និង ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៧១ ខាងលើនេះ។

## មាត្រា ១៧៥.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា ១៨០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទ ដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា ១៨១.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌ



ផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈ ចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា ១៨២.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ។

**មាត្រា ១៨៣.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ និងកថាខណ្ឌទី៣ នៃមាត្រា ៧៨ នៃច្បាប់នេះ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១៨៤.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ នៃមាត្រា ៧០ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា ១៨៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៨៤ ខាងលើនេះ។



**មាត្រា ១៨៦.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១៩១.-**

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងនៅក្នុងជំពូកនេះ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

បែបបទ និងនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១៩២.-**

ដំណើរការនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិ ដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ។

## មាត្រា ១៩៣.-

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិ-ទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តី-សម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ។



**ឧបសម្ព័ន្ធ គ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ថ្ងៃចន្ទ ១០កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

## ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអ្នកសារព័ត៌មានជាតិនៅ គ.ជ.ប | ថ្ងៃទី១៥ ខែកុម្ភៈ - ២៥ ខែឧសភា ឆ្នាំ២០២២ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិនៅ គ.ជ.ប | ថ្ងៃទី១៥ ខែកុម្ភៈ - ១ ខែមិថុនា ឆ្នាំ២០២២ |
| ៣ | ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅ គឃ.សប | ថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ |
| ៤ | ការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដោយ គឃ.សប រយៈពេល ៣ថ្ងៃ | ថ្ងៃទី៤-៦ ខែមីនា ឆ្នាំ២០២២ |
| ៥ | ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយរ យៈពេល ៧ថ្ងៃ | ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ៦ | ការកែតម្រូវលើពាក្យសុំចុះបញ្ជីបេក្ខជនដោយសាមីគណបក្សនយោបាយ រយៈពេល ៥ថ្ងៃ | ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ៧ | ការពិនិត្យសម្រេចលើការកែតម្រូវលើពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប | ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ |
| ៨ | ការប្តឹងតវ៉ាទាក់ទងនឹងការចុះបញ្ជីបេក្ខជនទៅ គធ.ខប រយៈពេល ៥ថ្ងៃ | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ៩ | ការសម្រេចលើពាក្យបណ្តឹងដោយ គធ.ខប រយៈពេល ៣ថ្ងៃ | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១០ | ការប្តឹងតវ៉ាទៅនឹងការចុះបញ្ជីបេក្ខជនទៅ គ.ជ.ប រយៈពេល ៥ថ្ងៃ | ថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១១ | ការសម្រេចលើពាក្យបណ្តឹងដោយ គ.ជ.ប រយៈពេល ៣ថ្ងៃ | ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១២ | ការបិទផ្សាយបញ្ជីបេក្ខជនដំបូងនៅ គឃ.សប រយៈពេល ៣ថ្ងៃ | ថ្ងៃទី៦-៨ ខែមេសា ឆ្នាំ២០២២ (ករណីមានបណ្តឹង) |
| ១៣ | ការប្តឹងជំទាស់នឹងបញ្ជីបេក្ខជនដំបូងទៅ គ.ជ.ប រយៈពេល ៣ថ្ងៃ | ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១៤ | ការដោះស្រាយពាក្យបណ្តឹងលើបញ្ជីបេក្ខជនដំបូងដោយ គ.ជ.ប រយៈពេល ៣ថ្ងៃ | ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១៥ | ការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅ គឃ.សប រយៈពេល ៧ថ្ងៃ | ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១៦ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយនៅ គឃ.សប | ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ១៧ | ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមភូមិក្នុងឃុំ សង្កាត់ | ថ្ងៃទី១៧ ខែមេសា -១៦ ខែឧសភា ឆ្នាំ២០២២ |
| ១៨ | ការឃោសនាបោះឆ្នោត រយៈពេល ១៤ថ្ងៃ | ថ្ងៃទី២១ ខែឧសភា -៣ ខែមិថុនា ឆ្នាំ២០២២ |
| ១៩ | ការបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត | ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២ |
| ២០ | ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ |
| ២១ | ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតដោយ គ.ជ.ប | ថ្ងៃទី៥-៦ ខែមិថុនា ឆ្នាំ២០២២ |
| ២២ | ការត្រួតពិនិត្យ ការបូកសរុប និងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៅ គឃ.សប រយៈពេល ៣ថ្ងៃ | ថ្ងៃទី៦-៨ ខែមិថុនា ឆ្នាំ២០២២ |
| ២៣ | ការប្តឹងជំទាស់លើលទ្ធផលបណ្តោះអាសន្នតាមឃុំ សង្កាត់ ទៅ គធ.ខប រយៈពេល ៣ថ្ងៃ | ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ២៤ | ការសម្រេចលើពាក្យបណ្តឹងជំទាស់ដោយ គធ.ខប រយៈពេល ៥ថ្ងៃ | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ២៥ | ការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប រយៈពេល ៥ថ្ងៃ | ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ២៦ | ការសម្រេចលើពាក្យបណ្តឹងតវ៉ាដោយ គ.ជ.ប រយៈពេល ៤ថ្ងៃ | ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ២៧ | ការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោត | ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |
| ២៨ | ការបោះឆ្នោតសាជាថ្មី (បើមាន) | ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ (ថ្ងៃចុងក្រោយ) |